# របាយការណ៍ប្រចាំឆមាសទី ១ ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម

## I. សេចក្ដីផ្ដើម

### 1. ស្ថានភាពភូមិសាស្ត្រ ខេត្តកំពង់ចាម

ខេត្តកំពង់ចាម ស្ថិតនៅដែនដីភាគខាងកើតប្រទេសកម្ពុជា ដែលមានចម្ងាយ ១២៤គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ខេត្តក៏មានផ្លូវជាតិសំខាន់ៗឆ្លងកាត់ដូចជា ផ្លូវជាតិលេខ 6A ផ្លូវជាតិលេខ 7 ដែលមានព្រំប្រទល់ខាងជើងជាប់ខេត្តកំពង់ធំ និងខេត្តក្រចេះ ខាងត្បូងជាប់ខេត្តព្រៃវែង ខេត្តកណ្ដាល ខាងកើតជាប់ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ខាងលិចជាប់ខេត្តកំពង់ឆ្នាំង ។

បច្ចុប្បន្នខេត្តកំពង់ចាមចែកចេញជា ស្រុក-ក្រុង ឃុំ-សង្កាត់ និងភូមិរដ្ឋបាល ដែលមានក្រុងចំនួន ០១ក្រុង មានសង្កាត់ ០៤សង្កាត់ និងស្រុកចំនួន ០៩ស្រុក មានឃុំចំនួន ១០៥ឃុំ ស្មើនឹង ៩១៦ភូមិ ។

ខេត្តកំពង់ចាមមានផ្ទៃដីសរុប ៤៥៤៨,០៩គ.ម² ហើយមានអំណោយផលធម្មជាតិយ៉ាងល្អប្រសើរដល់ដំណាំកសិកម្ម ដំណាំស្បៀងកសិឧស្សាហកម្មផងដែរ ។ ខេត្តកំពង់ចាម មានប្រជាពលរដ្ឋសរុប ១.០៩៧.០៨៥នាក់ ចំនួនស្ត្រីសរុប ៥៦២.០៨៥នាក់ ចំនួនគ្រួសារសរុប ២៥១.៤៥៨គ្រួសារ ដង់ស៊ីតេ ២៤១នាក់/គ.ម² ប្រជាកសិករប្រកបមុខរបរកសិកម្មចំនួន ៨0% មុខរបរសិប្បកម្ម 0.៨% សេវាកម្ម ១៦% មុខរបរមិនច្បាស់លាស់ (ចម្រុះ)៣.២០% ។

### 2. ស្ថានភាពរបស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានបង្កើតឡើងនៅឆ្នាំ១៩៩៤ រហូតដល់សព្វថ្ងៃមានការិយាល័យ ២០ ហើយចែកចេញជា ១០ការិយាល័យថ្នាក់ខេត្ត និង ១០ការិយាល័យថ្នាក់ស្រុក-ក្រុង ដោយមានមន្ត្រីសរុបចំនួន ៧២នាក់ ក្នុងនោះមានស្រីចំនួន ២០នាក់ ។ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ដឹកនាំដោយប្រធានមន្ទីរ ១រូប អនុប្រធានមន្ទីរ ០៨រូប និងប្រធាន-អនុប្រធានការិយាល័យមន្ទីរ និងថ្នាក់ស្រុកចំនួន ៦៤នាក់ ។

## II. សកម្មភាពតាមការិយាល័យនីមួយៗថ្នាក់ខេត្ត

### 1. ការងាររដ្ឋបាល និងបុគ្គលិក

បច្ចុប្បន្នមន្ទីរមានបុគ្គលិកក្របខ័ណ្ឌសរុបចំនួន ៧២នាក់ /ស្ត្រី ២០នាក់ គ្រប់គ្រងដោយប្រធានមន្ទីរ ០១រូប ទទួលបន្ទុកក្ដាប់រួម និងអនុប្រធានមន្ទីរចំនួន ០៨រូប ក្នុងនោះមានស្ត្រី ០១រូប ។

- ការិយាល័យទាំង ១០ មានបុគ្គលិកសរុប ៤៤នាក់/ស្ត្រីមាន ១២នាក់ ។
- ការិយាល័យអភិវឌ្ឍន៍ជនបទក្រុង និងស្រុកមានបុគ្គលិកសរុបចំនួន ២៨នាក់/ស្ត្រីចំនួន ០៩នាក់ ។
- ធ្វើលិខិតចេញបានចំនួន ២៨៩ច្បាប់ និងទទួលលិខិតចូលចំនួន ២៥២ច្បាប់ ។
- បានរៀបចំបញ្ជីវត្តមានប្រចាំថ្ងៃ ចំពោះមន្ត្រីការិយាល័យថ្នាក់ខេត្ត ។
- ធ្វើរបាយការណ៍ប្រចាំឆមាសទី១ ជូនសាលាខេត្ត និងក្រសួងទៀងទាត់រៀងរាល់ប្រចាំខែ ។

### 2. ការងារគណនេយ្យ និង ហិរញ្ញវត្ថុ

| ជំពូក | បរិយាយ | ស្ថានភាពឥណទានគិត (៛) | បណ្ដាខែមុន | ចំណាយក្នុងគ្រា | ចំណាយបូកយោង | សមតុល្យ |
|---|---|---|---|---|---|---|
| ៦០ | ការទិញ | 180,800,000 | 7,723,220 | 11,415,920 | 18,139,140 | 162,660,860 |
| ៦១ | សេវាខាងក្រៅ | 708,700,000 | 52,461,261 | 30,168,000 | 82,629,261 | 626,070,839 |
| ៦៤ | បន្ទុកបុគ្គលិក | 686,200,000 | 189,046,710 | 69,217,960 | 258,264,670 | 427,935,330 |
| | **សរុប** | 1,575,700,000 | 249,231,191 | 110,801,880 | 359,033,071 | |
| | | | | | | |

3. ការងារផែនការ និងស្ថិតិ

- រៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០១៥-២០១៧ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ជាមួយការិយាល័យហិរញ្ញវត្ថុ ។
- ចូលរួមកសាងផែនការអភិវឌ្ឍន៍រយៈពេល ០៥ឆ្នាំ ឆ្នាំ២០១៥-២០១៩ និងកម្មវិធីវិនិយោគ ០៣ឆ្នាំ រំកិល ២០១៥-២០១៧ របស់រដ្ឋបាលសាលាខេត្តកំពង់ចាម ។
- ចូលរៀបប្រជុំពិភាក្សា និងការងារធ្វើបច្ចុប្បន្នភាពសៀវភៅផែនការត្រៀមបង្ការឆ្លើយតបគ្រោះមហន្តរាយឆ្នាំ ២០១៥ ។

**អធិការកិច្ច**

- ថ្ងៃទី ២៣-២៤ ខែកុម្ភៈ ឆ្នាំ២០១៥ គណៈប្រតិភូអធិការកិច្ចក្រសួងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ដឹកនាំដោយលោក អួន ម៉េងឈាន់ ជាប្រធានគណៈប្រតិភូចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ក្នុងការិយបរិច្ឆេទឆ្នាំ២០១៤ បណ្ដាឆ្នាំបន្ទាប់ ។
- ថ្ងៃទី ២៧-៣០ ខែមេសា ឆ្នាំ២០១៥ គណៈប្រតិភូអគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ ដឹកនាំដោយលោក មាស ថាវ ប្រធានគណៈប្រតិភូចុះធ្វើសវនកម្មលើការគ្រប់គ្រងចំណាយ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការអនុលោមតាមបទប្បញ្ញត្តិ និងប្រព័ន្ធគ្រប់គ្រងសម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៤ និងឆ្នាំពាក់ព័ន្ធ ។
- ថ្ងៃទី ២៦-២៨ ខែឧសភា ឆ្នាំ២០១៥ គណៈប្រតិភូអធិការកិច្ចក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយលោក សួត ប៊ុនសាន ប្រធានគណៈប្រតិភូចុះធ្វើអធិការកិច្ចលើការងារ ការគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋ ថវិកាបដិភាគ ថវិកាជំនួយផ្សេងៗ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ចំណូលសារពើពន្ធ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកាតព្វកិច្ចត្រូវបង់ចំណូលចូលរដ្ឋ ក្នុងការិយបរិច្ឆេទ ឆ្នាំ២០១៤។

**កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ:**

- ប្រធាន-អនុប្រធានមន្ទីរ និងមន្ត្រីរាជការមួយចំនួនបានចូលរួមប្រជុំផ្សេងៗចំនួន ១៧៩លើក ។

III. **សកម្មភាពតាមវិស័យ**

1. ការិយាល័យផ្លូវលំជនបទ

- ការងារថែទាំលក្ខណៈខួបមានចំនួន ០៣ខ្សែ ប្រវែង ២២.០៣០គ.ម ស្ថិតនៅស្រុកជើងព្រៃ ស្រុកព្រៃឈរ ខេត្តកំពង់ចាម (កំពុងចរចាថ្លៃ) ។

- ការងារកែលម្អផ្លូវក្រាលគ្រួសក្រហមទៅជាផ្លូវកៅស៊ូ DBST នៅព្រៃកដើមចាន់ ទៅវត្តថ្មី មានប្រវែង ២.០៨០គ.ម ស្ថិតនៅឃុំសំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម កំពង់ដំណើរការសាងសង់ ។

★ ការិយាល័យផ្លូវលំជនបទក្នុងឆមាសទី១ នេះ មន្ត្រីជំនាញនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានចុះសិក្សាផ្លូវបេតុងរបស់គម្រោង (ADB) RRIP បានចំនួន ០៣ខ្សែ ប្រវែង ៤៥.២៥គ.ម ស្ថិតនៅស្រុកកំពង់សៀម និងស្រុកកោះសូទិន ខេត្តកំពង់ចាម មានដូចខាងក្រោម÷

- សិក្សាផ្លូវបេតុងប្រវែង ១១.៥៥០គ.ម ស្ថិតនៅឃុំសំរោង ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។
- សិក្សាផ្លូវបេតុងប្រវែង ១៤.៧៨០គ.ម ស្ថិតនៅឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។
- សិក្សាផ្លូវបេតុងប្រវែង ១៨.៩២០គ.ម ស្ថិតនៅឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

**១-ការងារសាងសង់ផ្លូវអនុវត្តដោយគម្រោង RIP**

- ផ្លូវដីក្រាលគ្រួសក្រហមប្រវែង ១.៨៣២គ.ម និងស្ពាន ០១កន្លែង ប្រវែង ២០ម៉ែត្រ ស្ថិតនៅឃុំកោះរការ ស្រុកកំពង់សៀម ខេត្តកំពង់ចាម លទ្ធផលសម្រេចបាន ៩០% ។
- ផ្លូវដីក្រាលគ្រួសក្រហមប្រវែង ៣.៩៣៩គ.ម ដែលស្ថិតនៅឃុំស្ដើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម លទ្ធផលសម្រេចបាន ៩០% ។
- ផ្លូវភ្ជឹ ០១កន្លែង សាងសង់ដោយគម្រោង RIP ស្ថិតនៅឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម លទ្ធផលសម្រេចបាន ៧០% ។

**២-ការងារជួសជុលផ្លូវក្រាលគ្រួសក្រហមដោយទឹកជំនន់ឆ្នាំ ២០១៣ និងឆ្នាំ ២០១៥**

- ជួសជុលផ្លូវក្រាលគ្រួសក្រហម ប្រវែង ៥.៩៥០គ.ម ស្ថិតនៅឃុំព្រៃចារ ស្រុកជើងព្រៃ លទ្ធផលសម្រេចបាន ១០០% ។
- ជួសជុលផ្លូវក្រាលគ្រួសក្រហមប្រវែង ២គ.ម និងលូប្រអប់ ២កន្លែង ស្ថិតនៅឃុំបារាយ និងឃុំព្រៃករំដេង ស្រុកស្រីសន្ធរ លទ្ធផលសម្រេចបាន ១០០% ។

**៣-ការងារថែទាំជាលក្ខណៈខួបរបស់គម្រោង RIP**

- ផ្លូវក្រាលគ្រួសក្រហមប្រវែង ១៥គ.ម ស្ថិតនៅឃុំល្វាលើ និងតាប្រុក ស្រុកចំការលើ លទ្ធផលសម្រេចបាន ៩០% ។

2. <u>ការងារផ្គត់ផ្គង់ទឹកស្អាតជនបទ</u>

ការិយាល័យផ្គត់ផ្គង់ទឹកជនបទ ក្នុងឆមាសទី១ ឆ្នាំ២០១៥ បានសិក្សាទីតាំងសម្រាប់ជីកអណ្តូង អាងត្រង់ទឹកភ្លៀង ជួសជុលអណ្តូងស្នប់ ជីកស្រះ ស្ពានប្រឡាយ ÷

**១-ការងារជីកអណ្តូងស្នប់ (ចរិកាជាតិ) ចំនួន ១២អណ្តូង គឺ៖**

| | | | | |
|---|---|---|---|---|
| - ស្រុកចំការលើ | ឃុំបុសខ្នុរ | ភូមិបារាយ | ចំនួន | ០២អណ្តូង |
| | | ភូមិថ្លុកក្រវ៉ាន់ | ចំនួន | ០២អណ្តូង |
| - ស្រុកព្រៃឈរ | ឃុំមៀន | ភូមិកំពង់សិរិទ្ធ | ចំនួន | ០១អណ្តូង |
| | | ភូមិជ្រៃវៀន | ចំនួន | ០២អណ្តូង |

- ក្រុងកំពង់ចាម ឃុំសំបួរមាស ភូមិតាណោង ចំនួន ០១អណ្តូង
- ស្រុកកោះសូទិន ឃុំពាមប្រធ្នោះ ភូមិផ្សារថ្មី ចំនួន ០១អណ្តូង
  ឃុំពង្រ ភូមិកពង់ឪច្រឹង ចំនួន ០១អណ្តូង

២-ការងារស្តារប្រឡាយ នៅស្រុកកោះសូទិន ÷

- ចុះសិក្សាទីតាំងស្តារប្រឡាយចំនួន ០១ខ្សែ ប្រវែង ១,៥០០ម៉ែត្រ មានកំណាត់ ក្នុង ០១កំណាត់ មាន ប្រវែង ២០០ម៉ែត្រ ។ កំណាត់ទី១ ភូមិព្រែកសង្កែ ឃុំល្វេ ប្រវែង ២០០ម៉ែត្រ និងប្រវែង ៣កំណាត់ទៀត ស្ថិតនៅភូមិល្វេលើ ភូមិទំពូង ឃុំល្វេ ប្រវែង ១,៣០០ម៉ែត្រ ។

**៣-ការងារសាងសង់អាងត្រង់ទឹកភ្លៀងចំណុះ ៣៥ម៣ ចំនួន ០២អាង ៖**

- ស្រុកចំការលើ ឃុំបុសខ្នុរ សាលាបឋមសិក្សាដូនធី ចំនួន ០១អាង
- ស្រុកព្រៃឈរ ឃុំត្រពាំងព្រះ សាលាមឋមសិក្សានរោត្តមរ៉ាមរិទ្ធិ ចំនួន ០១អាង

**៤- ការងារជីកស្រះសហគមន៍ ទំហំ (៥០ម x៣០ម x៣ម)**

- ស្រុកស្ទឹងត្រង់ ឃុំទួលព្រះឃ្លាំង ភូមិវត្ត ចំនួន ០១ស្រះ

**៥- ការងារជួសជុលអណ្តូងស្នប់ អាហ្វ្រីដេស ចំនួន ៣៥អណ្តូង**

- ស្រុកបាធាយ ឃុំសណ្តែក ចំនួន ០៦អណ្តូង
  ឃុំទំនប់ ចំនួន ០២អណ្តូង
  ឃុំតាំងត្រសាំង ចំនួន ១០អណ្តូង
  ឃុំមេព្រីង ចំនួន ០៨អណ្តូង

**៦- ការងារសហការជាមួយអង្គការទឹកភ្លៀងកម្ពុជា សាងសង់អាងត្រង់ទឹកភ្លៀងចំនួន ១៦អាង៖**

- ស្រុកស្រីសន្ធរ សាលារៀនខ្សែ ចំនួន ០១អាង
  សាលាស្វាយសាច់ភ្នំ ចំនួន ០១អាង
- ស្រុកកំពង់សៀម សាលាបឋមសិក្សាកំពង់ក្របី ចំនួន ០១អាង
  សាលាបឋមសិក្សាកោះគល់ ចំនួន ០១អាង
  សាលាបឋមសិក្សាកោះប៉ែន ចំនួន ០១អាង
- ស្រុកកងមាស សាលាបឋមសិក្សាស្តៅ ចំនួន ០១អាង
  សាលាបឋមសិក្សារការគយ ចំនួន ០១អាង
  សាលាបឋមសិក្សាបឹងត្រាវ ចំនួន ០១អាង
- ស្រុកកោះសូទិន សាលាបឋមសិក្សាកោះថ្មី ចំនួន ០១អាង
  វត្តទីប្រជុំ ចំនួន ០១អាង
  សាលាបឋមសិក្សាឃុំសំរោង ចំនួន ០១អាង
  សាលាបឋមសិក្សាកោះចិន ចំនួន ០១អាង
  សាលាបឋមសិក្សាអង្គរជ័យ ចំនួន ០១អាង

សាលាបឋមសិក្សាព្រែកតានង់ ចំនួន ០១អាង

សាលាបឋមសិក្សាកំពង់ចំបក់ ចំនួន ០១អាង ។

៧- **ការងារសហការជាមួយអង្គការ** UNICEF ស្តារអណ្តូង គ្រោះមហន្តរាយទឹកជំនន់ចំនួន ២៥អណ្តូង និងផ្លាស់ប្តូរក្បាលស្នប់ថ្មីចំនួន ១០អណ្តូង ÷

- ស្រុកកោះសូទិន ជួសជុលអណ្តូងស្នប់ អាហ្វីដេស ចំនួន ០៤អណ្តូង
- ស្រុកកំពង់សៀម ជួសជុលអណ្តូងស្នប់ អាហ្វីដេស ចំនួន ១០អណ្តូង
- ស្រុកកងមាស ជួសជុលអណ្តូងស្នប់ អាហ្វីដេស ចំនួន ១០អណ្តូង
- ស្រុកកោះសូទិន ឃុំមហាលាភ ផ្លាស់ប្តូរស្នប់ថ្មី ចំនួន ០២អណ្តូង
- ស្រុកកងមាស ឃុំព្រែកក្របៅ ផ្លាស់ប្តូរស្នប់ថ្មី ចំនួន ០៨អណ្តូង

៨- **ការងារសហការជាមួយនាយកដ្ឋានថែទាំសុខភាព**

ចុះសម្ភាសន៍ជាមួយអ្នកលក់ទឹកតាមផ្ទះ តាមប្រព័ន្ធទុយោ ដើម្បីបង្រឹងសមត្ថភាពធ្វើទឹកអោយស្អាតបានចំនួន ២៨ស្ថានីយ៍ មានស្រុក÷

- ស្រុកស្រីសន្ធរ ចំនួន ១៣ស្ថានីយ៍
- ស្រុកកងមាស ចំនួន ០៣ស្ថានីយ៍
- ស្រុកកោះសូទិន ចំនួន ០៧ស្ថានីយ៍
- ស្រុកកំពង់សៀម ចំនួន ០៥ស្ថានីយ៍

3. <u>ការងារថែទាំសុខភាពជនបទ</u>

- ចូលរួមកិច្ចប្រជុំនៅ OFFICE UNICEF ស្តីពី គំរូប្លង់អណ្តូងដែលត្រូវជួសជុលស្តារឡើងវិញក្រោយទឹកជំនន់ ។
- ចូលរួមធ្វើទិវាថ្នាក់ឃុំ ស្តីពី ការគ្រប់គ្រង និងលើកកម្ពស់អនាម័យជនបទ នៅស្រុកកងមាស ខេត្តកំពង់ចាម ។
- ចុះបើកវគ្គបណ្តុះបណ្តាលកម្មវិធី ទឹកស្អាត និងអនាម័យតាមសាលារៀនចំនួន ១០សាលា មានអ្នកចូលរួមបានចំនួន ១៩៦នាក់/ស្រី ៨០នាក់ ។
- ចុះសង្កេតមើលការបំផុសអនាម័យបន្តពីគ្រូ ទៅសិស្ស លោកគ្រូ អ្នកគ្រូ ចូលរួម ៤០នាក់ /ស្រី ១៨នាក់ ស្មើនឹង ១០សាលា សិស្សានុសិស្សចំនួន ៧៣៦នាក់ /ស្រី ៣៨២នាក់ ក្នុងនោះមានស្រុកកំពង់សៀម ស្រុកកោះសូទិន ស្រុកកងមាស និងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។
- ចុះបំផុសអនាម័យតាមសាលាដល់សិស្ស ចំនួន ១០សាលា ចំនួនគ្រូ ៤០នាក់ /ស្រី ១៥នាក់ និងសិស្សចំនួន ៧៣៦នាក់/ស្រី ៣៨២នាក់ ស្មើនឹង ១០ឃុំ ស្មើ ៤ស្រុក ។
- ចុះពិនិត្យ និងវាយតម្លៃអនាម័យតាមសាលាចំនួន ១០សាលា ស្មើនឹង ១០ឃុំ មាន ៤ស្រុក មានគ្រូចូលរួមចំនួន ២០នាក់/ស្រី ០៩នាក់ ។ ការវាយតម្លៃជារួមឃើញថា តាមសាលាមានកំណើនអនាម័យល្អប្រសើរច្រើន ។
- ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមប្រជុំការងារប្រចាំ ខែមករា ឆ្នាំ២០១៥ និងទិសទៅបន្ត ។
- ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៥ ចុះបើកវគ្គបណ្តុះបណ្តាល ធ្វើអោយប្រសើរឡើងផ្នែកទឹកស្អាត និងអនាម័យតាមសាលារៀន និងសហគមន៍ នៅស្រុកកោះសូទិន ។

- ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៥ ចូលរួមប្រជុំផ្សព្វផ្សាយពីអនាម័យដល់ប្រជាពលរដ្ឋក្រ១ +ក្រ២ ជាមួយអង្គការលោកខាងលិច និងជួបលោកខាងកើត ។
- ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៥ ចុះផ្សព្វផ្សាយអនាម័យដល់ប្រជាពលរដ្ឋក្រ១ +ក្រ២ នៅភូមិប្រាសាទ ឃុំវិហារធំ ស្រុកកំពង់សៀម ខេត្តកំពង់ចាម មានអ្នកចូលរួម ២៤នាក់ ស្រុក ២០នាក់ ។
- ថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៥ បានចុះស្រង់របាយការណ៍បង្គន់ចាក់ទឹកចំនួន ៨៣៦៥បង្គន់ និងបង្គន់ចាក់ផេះចំនួន ២៨១បង្គន់ ស្ថិតនៅស្រុកកងមាស ខេត្តកំពង់ចាម ។
- ថ្ងៃទី ០៨-១០ ខែមេសា ឆ្នាំ២០១៥ បានចុះទៅភូមិត្រពាំងកក់ ភូមិអូរស្វាយ ភូមិព្រៃចក្រី ឃុំអូរស្វាយ ស្រុកកំពង់សៀម ដើម្បីពន្យល់ណែនាំអ្នកក្រ១ និងក្រ២ ធ្វើបង្គន់ប្រើប្រាស់ដោយគម្រោងរបស់អង្គការ EMW ។
- ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៥ បានចុះជាមួយអង្គការ EMW ទៅជួបលោកមេឃុំវិហារធំ និងជនបង្គោលភូមិប្រាសាទ និងភូមិគោកក្រោម ស្រុកកំពង់សៀម ដើម្បីផ្សព្វផ្សាយពីកម្មវិធីរបស់គម្រោង និងសួរពីបញ្ហាប្រឈមមូលហេតុធ្វើបង្គន់ ដែលមានអ្នកចូលរួម ៣៦នាក់/ស្រី ២៣នាក់ ។
- ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៥ ចុះសហការជាមួយអង្គការ NAS ទៅឃុំអូរម្លូ ស្រុកស្ទឹងត្រង់ ដើម្បីពន្យល់បង្ហាញពីគម្រោងលើកកម្ពស់អនាម័យបឋម ក្នុងសហគមន៍ជនបទ ទៅដល់ជនបង្គោលភូមិ-ឃុំ ។
- ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១៥ ចុះទៅភូមិខែលជ័យ ឃុំអូរស្វាយ ស្រុកកំពង់សៀម ដើម្បីធ្វើការផ្សព្វផ្សាយពីអនាម័យជនបទ ដែលមានការសហការជាមួយអង្គការ NAS តាមដានត្រួតពិនិត្យភូមិ CLTS ទៅភូមិត្រពាំងបី ឃុំបារាយ ស្រុកព្រៃឈរ និងចុះទៅភូមិអូរកំបោរ ឃុំបារាយ ស្រុកព្រៃឈរ ដែលមានអ្នកចូលរួម ១៧នាក់ /ស្រី ១១នាក់ ។

4. <u>ការងារអភិវឌ្ឍន៍សហគមន៍ជនបទ</u>

- ថ្ងៃទី ១០-១៥ ខែកុម្ភៈ ឆ្នាំ២០១៥ ចុះផ្សព្វផ្សាយពីអនាម័យ នៅស្រុកព្រៃឈរ ។
- ចុះតាមដាន និងពង្រឹងសម្ថភាព (គ.អ.ភ) ចំនួន ០៣លើក ក្នុងភូមិគោលដៅចំនួន ១៥ភូមិ ឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។
- ថ្ងៃទី ១៦-២០ ខែកុម្ភៈ ឆ្នាំ២០១៥ ចុះតាមដាន និងពង្រឹងសម្ថភាព (គ.អ.ភ) បានចំនួន ០៥ភូមិ ក្នុងឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។
- ថ្ងៃទី ២៣-២៧ ខែកុម្ភៈ ឆ្នាំ២០១៥ ចុះតាមដាន និងពង្រឹងសម្ថភាព (គ.អ.ភ) បានចំនួន ០៥ភូមិ ក្នុងឃុំ ត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។
- ចុះតាមដាន និងពង្រឹងសម្ថភាព (គ.អ.ភ) ចំនួន ០៧លើក ក្នុងភូមិគោលដៅចំនួន ៣៤ភូមិ ឃុំត្រពាំងព្រះ និងឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

5. <u>ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ</u>

១- គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ

- ស្រុកចំនួន ០៤ស្រុក ឃុំចំនួន ១៤ឃុំ ភូមិចំនួន ៤២ភូមិ
- អតិថិជនសរុបចំនួន ៨៥៣នាក់ ស្រីចំនួន ៧២៤នាក់

- ក្រុមចំនួន ៤៥៤ក្រុម
- ប្រាក់ដើមឱ្យខ្ចីចំនួន ១៤១,១០០,០០០រៀល
- ប្រាក់ដើមសងចំនួន ១៦១,៦៨០,៤០០រៀល
- ប្រាក់ការសងចំនួន ២៩,៣៥៧,១០០រៀល
- ប្រាក់ដើមនៅជំពាក់ចំនួន ១,៣៨៦,៧២៤,៨០០រៀល

២ - គម្រោងឥណទានកូវ៉េ

- ស្រុកចំនួន ០១ស្រុក ឃុំចំនួន ០១ឃុំ ភូមិចំនួន ០៤ភូមិ
- អតិថិជនសរុបចំនួន ២៥៩នាក់ ស្រីចំនួន ២០០នាក់
- ក្រុមចំនួន ៨៤ក្រុម
- ប្រាក់ដើមឱ្យខ្ចីចំនួន ២០,៨០០,០០០រៀល
- ប្រាក់ដើមសងចំនួន ៣១,៦៣០,៣០០រៀល
- ប្រាក់ការសងចំនួន ៤,៥៤០,៣០០រៀល
- ប្រាក់ដើមនៅជំពាក់ចំនួន ២១៧,៤៨០,២០០រៀល

6. <u>ការងារអភិវឌ្ឍន៍បណ្តុះបណ្តាល និងស្រាវជ្រាវ</u>

ដោយមានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីបង្កើនជំនាញជូនដល់ប្រជាពលរដ្ឋក្រីក្រ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានចាប់ផ្តើមបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញមូលដ្ឋាន សំដៅឱ្យយុវជន យុវនារីក្រីក្រ កំព្រា ដែលមិនអាចមានលទ្ធភាពបន្តការសិក្សាទៅមុខទៀតដើម្បីឱ្យពួកគេមានជំនាញមួយពិតប្រាកដ ។ ហើយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញមូលដ្ឋាន បានធ្វើការផ្សព្វផ្សាយទៅដល់ភូមិ-ឃុំ តាមរយៈមន្រ្តីការិយាល័យស្រុក-ក្រុង ទាំង ០៩ស្រុក ០១ក្រុង ខេត្តកំពង់ចាម និងបានផ្សព្វផ្សាយតាមវិទ្យុខេត្ត ដើម្បីជ្រើសរើសសិស្សចូលរៀនតាមមុខជំនាញ ។

❷ ការងារបណ្តុះបណ្តាលក្នុងមជ្ឈមណ្ឌល

នៅក្នុងឆមាសទី១ ឆ្នាំ២០១៥ មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ខេត្តកំពង់ចាម បានបើកវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានដូចខាងក្រោម÷

| | | | | |
|---|---|---|---|---|
| - | ជំនាញកុំព្យូទ័ររដ្ឋបាលចំនួន | ១៥នាក់ | ស្រី | ០៩នាក់ |
| - | ជំនាញជួសជុលម៉ូតូចំនួន | ០៨នាក់ | ស្រី | ០នាក់ |
| - | ជំនាញកែសម្ផស្ស និងអ៊ុតសក់ចំនួន | ១១នាក់ | ស្រី | ១១នាក់ |
| សរុប | មានសិក្ខាកាមចំនួន | ៣៤នាក់ | ស្រី | ២០នាក់ |

❷ មន្ត្រីរាជការដែលកំពុងសហការជាមួយអង្គការអន្តរជាតិ និងអង្គការជាតិ

- គម្រោងឥណទាន ក្រសួងអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម ១៥នាក់
- អង្គការ ADB ០៦នាក់
- អង្គការយូនីសេហ្វ (UNICEF) ០៥នាក់
- កម្មវិធី RIP ០៤នាក់

❷ ការងារសហាការជាមួយអង្គការ NGOs

- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានសហាការណ៍ជាមួយអង្គការដៃគូមួយចំនួនដែលទទួលបានការគាំទ្រពី មូលនិធិអនាម័យសកល )Global Sanitation Fund) មានដូចជា អង្គការ Plan អង្គការទឹកភ្លៀង អង្គការ SNV អង្គការ NAS អង្គការ CHED អង្គការទឹកស្អាត ១០០១ អង្គការ Water SHED និងអង្គការ UNICEF អប់រំអនាម័យតាមសាលារៀន និងសហគមន៍មូលដ្ឋាន ។

❷ គម្រោងឧបត្ថម្ភស្បៀងបន្ទាន់

- ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមសិក្ខាសាលាបញ្ចប់កម្មវិធីផ្នែកសុខភាព អាហាររូបត្ថម្ភ បំណិនជីវិត និងអនាម័យក្រោមគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ ហិរញ្ញប្បទានបន្ថែម នៅសាលាខេត្តកំពង់ធំ ។
- សិក្ខាសាលាបញ្ចប់គម្រោងអង្គការភ្លែន និងអង្គការដៃគូ ស្តីពី ការប្រតិបត្តិកម្មវិធីបំណិនជីវិត និងអាហាររូបត្ថម្ភដល់មាតា និងទារកក្រោមគម្រោងឧបត្ថម្ភស្បៀងបន្ទាន់-ហិរញ្ញប្បទានបន្ថែម ។

❷ ការងារអង្គការយូនីសេហ្វ

- ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៥ មានកិច្ចប្រជុំប្រចាំត្រីមាសលើកទី២ ជាមួយអ្នកពាក់ព័ន្ធគម្រោង ក្រោមហិរញ្ញប្បទានរបស់អង្គការយូនីសេហ្វ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ។
- ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៥ មានកិច្ចប្រជុំប្រចាំត្រីមាសលើកទី២ ជាមួយអ្នកពាក់ព័ន្ធគម្រោង ក្រោមហិរញ្ញប្បទានរបស់អង្គការយូនីសេហ្វ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ។
- ថ្ងៃទី ២៦-២៧ ខែកុម្ភៈ ឆ្នាំ២០១៥ លោកស្រី ប៊ុន ស្រ៊ីម មន្ត្រីការិយាល័យសុខភាពជនបទ បានចូលរួមដំណើរទស្សនៈកិច្ចសិក្សា ស្តីពី ការលើកកម្ពស់អនាម័យជនបទ )HPនិង (ការត្រៀមបង្ការគ្រោះទឹកជំនន់ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។
- ថ្ងៃទី ១០-១១ ខែមីនា ឆ្នាំ២០១៥ មន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ចំនួន ០៤រូប ចូលរួមកិច្ចប្រជុំលើកកម្ពស់អនាម័យជនបទ (HP) និងការត្រៀមបង្ការគ្រោះទឹកជំនន់ នៅខេត្តកំពង់ឆ្នាំង ។
- ថ្ងៃទី ៣០-៣១ ខែមីនា ឆ្នាំ២០១៥ មន្ត្រីជំនាញ ០២រូប នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានចូលរួមប្រជុំបូកសរុបលទ្ធផលការងារសម្រេចបានក្នុងឆ្នាំ ២០១៤ សម្រាប់កម្មវិធីកាត់បន្ថយសារធាតុអាសេនិក និងការបន្សុទ្ធ ការស្តុកទឹកទុកឱ្យមានសុវត្ថិភាពតាមគ្រួសារ និងការរៀបចំផែនការសម្រាប់ត្រីមាសទី១ ឆ្នាំ ២០១៥ នៅសាលមន្ទីរពេទ្យកុមារជាតិ រាជធានីភ្នំពេញ ។

❷ ការងារយេនឌ័រ

- ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៥ លោក អ៊ឹង ចាន់ណារ៉េត អនុប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំប្រចាំខែមករា របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត នៅសាលាខេត្តកំពង់ចាម ។
- ថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៥ លោកប្រធានមន្ទីរ លោកស្រីអនុប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំលើកទី៣៣ របស់គណៈកម្មាធិការសម្របសម្រួលគម្រោងសាកល្បង នៅមន្ទីរកិច្ចការនារី ខេត្តកំពង់ចាម ។
- ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៥ លោកប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំលើកទី៦ របស់គណៈកម្មាធិការសម្របសម្រួលរួម (JCC) នៅសណ្ឋាគារភ្នំពេញ ។

- ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០១៥ លោក អ៊ឹង ចាន់ណារ៉េត អនុប្រធាន ចូលរួមកិច្ចប្រជុំប្រចាំខែមករា របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត នៅសាលាខេត្តកំពង់ចាម ។
- ថ្ងៃទី ០៣-០៤ ខែមិថុនា ឆ្នាំ២០១៥ លោកស្រីអនុប្រធានមន្ទីរ ចូលរួមសិក្ខាសាលា ស្ដីពី ការផ្ដល់អនុសាសន៍សម្រាប់គោលនយោបាយរបស់គម្រោងបញ្ញាបយេនឌ័រដំណាក់កាលទី២ )PGM2) នៅរាជធានីភ្នំពេញ ។

7. ការិយាល័យជនជាតិដើមភាគតិច

## IV. ទិសដៅផែនការឆ្នាំ ២០១៥

មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម បានខិតខំប្រឹងប្រែងពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នជាតិ អង្គការ សហគមន៍នានា ឱ្យមានភាពកាន់តែប្រសើរឡើង ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋមានលក្ខណៈសមស្របពីមួយថ្ងៃទៅមួយថ្ងៃ និងស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

## V. បញ្ហាប្រឈម

ស្របតាមសមិទ្ធផលដែលទទួលបានពីអនុវត្តន៍ការងារក្នុងឆ្នាំកន្លងមក មន្ទីរបានកត់សម្គាល់ឃើញថា មានការប្រឈមមួយចំនួននៅពេលចុះអនុវត្តន៍ការងារដូចជា ÷

- ការពង្រឹងធនធានមនុស្សដល់មន្ត្រីមន្ទីរនូវមានកម្រិត ព្រោះការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស នៅពុំទាន់បានសមស្របតាមផ្លូវការ ។
- ការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិត ក្នុងការថែទាំសមិទ្ធផលដែលបានផ្ដល់ការយល់ដឹងរបស់ប្រជាពលរដ្ឋ លើការថែទាំសុខភាព និងអនាម័យ អប់រំផ្សព្វផ្សាយបានទូលំទូលាយ ការផ្លាស់ប្ដូរទម្លាប់របស់សហគមន៍នៅមានភាពយឺតយ៉ាវ ។

## VI. សន្និដ្ឋាន

យោងតាមរបាយការណ៍អនុវត្តន៍គោលនយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍បានបង្ហាញឱ្យឃើញថា ដើម្បីអនុវត្តន៍ផែនការអភិវឌ្ឍន៍ជនបទ បានសម្រេចលុះត្រាតែយើងបានអនុវត្តនូវសកម្មភាពដូចខាងក្រោម÷

- ធ្វើអោយមានសកម្មភាពឡើងវិញនូវគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ដែលត្រូវបានចំណាត់ថ្នាក់ជាអាទិភាពនៅក្នុងគោលនយោបាយអភិវឌ្ឍន៍ជនបទ ។
- ការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា សំណង់ធារាសាស្ត្រ ផ្លូវជនបទ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។ ដោយអនុវត្តន៍គោលនយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជនបទ របស់មន្ទីរបានបង្ហាញឱ្យឃើញថា ខេត្តកំពង់ចាម ទទួលបានការអភិវឌ្ឍន៍ដូចជា ស្ពាន និងផ្លូវលំជនបទខ្វាត់ខ្វែងសម្រាប់ប្រជាពលរដ្ឋធ្វើចរាចរណ៍ក្នុងការដឹកនាំកសិផលដែលជាកត្តា ធ្វើអោយប្រជាពលរដ្ឋកាន់តែជិតរវាងជនបទ និងទីប្រជុំជន ។ ធ្វើ

ឱ្យប្រជាជនមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រើប្រាស់ ជាពិសេសធ្វើអោយយល់ដឹងពីសុខភាព និងអនាម័យ តាមរយៈការអប់រំផ្សព្វផ្សាយ និងប្រើប្រាស់បង្គន់អនាម័យ ។

សរុបសេចក្តីមក យើងឃើញថា ការអនុវត្តន៍គោលនយោបាយ និងផែនការអភិវឌ្ឍន៍ជនបទ បានចូលរួមអនុវត្តន៍ឱ្យបាន ជោគជ័យនូវយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ អាណត្តិទី៥ និងគោលនយោបាយ ស្តីពី ការផ្តល់សេវាសាធារណៈរបស់ រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង សំដៅលើកកម្ពស់ជីវភាពរបស់ ប្រជាពលរដ្ឋតាមរយៈការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ធ្វើឱ្យប្រជាពលរដ្ឋមានលំនៅខំណ្ឌល្អប្រសើរ ក្នុងជីវភាពរស់នៅ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ។

**ប្រធានមន្ទីរ**